ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ធំ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៧
ចុះថ្ងៃទី៣០.ឧសភា.២០២៣
សំណុំរឿងជម្រះលេខ ៣៥៥/១៨.០៩.២៣
សាលក្រមព្រហ្មទណ្ឌលេខ.១៧ "ខ"
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ធំ

-បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ធំ
កាលបរិច្ឆេទ: បើកសវនាការនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤
និងប្រកាសសាលក្រមនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤។

## ដោយមានសមាសភាពដូចតទៅ:

## ចៅក្រមជំនុំជម្រះ

លោក [redacted] ជាអនុប្រធាន និងជាចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកំពង់ធំ

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ធំ

## ដើម្បីជំនុំជម្រះ

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៧ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ:

ឈ្មោះ [redacted] ម៉ារី ភេទស្រី អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ ឃោផា មានទីកន្លែងកំណើត [redacted] និងរស់នៅ [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] សុផាន់ (រ) ម្តាយឈ្មោះ [redacted] ឡុង (រ) ប្តីឈ្មោះ [redacted] ស្រ៊ាន់ (លែងលះ) មានកូន ០២នាក់។

ជាបចោទពីបទ "បរិហាកេរ្តិ៍ជាសាធារណៈ, ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍, ញុះញង់ឲ្យមានការរើសអើង និងស្អប់ខ្ពើមថ្នាក់ដឹកនាំ និងស្ថាប័នក្រសួងការពារជាតិ" ប្រព្រឹត្តនៅតាមបណ្តាញFacebook name Mary Ka និងTelegram កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ រហូតដល់មានបណ្តឹង តាមបញ្ញត្តិមាត្រា៤៩៤, មាត្រា៤៩៥, មាត្រា ៣០៥ និងមាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងពីបទ "ឆបោក" ប្រព្រឹត្តនៅទីស្តីការក្រសួងការពារជាតិ ស្ថិតនៅសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-ដែលមានលោកមេធាវី [redacted] លោកមេធាវី [redacted], លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។



Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណី៖

+ឈ្មោះ [redacted] សុផាត ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]។

+ឈ្មោះ [redacted] ឆ័យណារ ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅ [redacted]។

-ដែលមានមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងឈ្មោះ [redacted] អត្តលេខ ១១១២ និងមេធាវីឈ្មោះ [redacted] អត្តលេខ ២០៩៩។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៦២ /២៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការខេត្តកំពង់ធំ។

-បានឃើញ ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៣០០៩/២០២៣ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ធំ។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ មានគណនី Facebook name [redacted] ដែលជាគណនីរបស់ឈ្មោះ [redacted] ម៉ារី ភេទស្រី អាយុ ៣៧ឆ្នាំ មានទីលំនៅ [redacted] ដែលបានបង្ហោះខ្លឹមសារចោទប្រកាន់ និងបំផ្លើសខុសពីការពិតដោយមានភ្ជាប់នូវរូបភាពរបស់ឈ្មោះ [redacted] ឆ័យណារ និងថ្នាក់ដឹកនាំរបស់ក្រសួងការពារជាតិ និងថ្នាក់ដឹកនាំកំពូលៗផ្សេងទៀតថា "ថ្ងៃមុនទៅប៉ោយប៉ែតប្តឹងប៉ូលីសចរាចរណ៍រឿងបោកលុយខ្លួន ចំនួន ៣៥.០០០$ ខណៈពេលនោះមានអ្នកចេញមុខតតាំងនាមជាកូនថ្នាក់ដឹកនាំឈ្មោះ [redacted] ផាត និងជាជំនួយការកូនថ្នាក់ដឹកនាំធំទី១ម្នាក់ទៀតមកគំរាមខ្លួនឱ្យដកពាក្យបណ្តឹងព្រោះគេទទួលការពឹងពាក់ឱ្យជួយសម្រួលដាច់ខាតឱ្យខ្លួនដកពាក្យបណ្តឹងជាបន្ទាន់ ស្តាប់ឮហើយរូបខ្លួនភ័យញ័រជើងហ្នឹងសូមជម្រាបជូនអស់លោកជ្រាប បើមិនទាន់សងលុយខ្លួនទេ, កុំសង្ឃឹមថា ខ្លួនបញ្ចប់រឿងហើយដកពាក្យបណ្តឹងអីត្រឹមស្ត្រីមេម៉ាយម្នាក់គ្មានខ្នងបង្អែក គ្មានខ្សែអ្នកធំចាំជួយដូចអ្នកទេ, តែខ្លួនត្រូវប្តឹងទាមទាររកខុសត្រូវសខ្មៅឱ្យខ្លួនឯងបានយុត្តិធម៌វិញ, ខ្លួនមិនធ្លាប់ខ្លាចអំណាចបុណ្យស័ក្តអ្នកណាទេ បើខ្លួនមិនខុស ....សង្ឃឹមថាថ្នាក់ដឹកនាំធ្វើជាគំរូល្អ កុំកាន់ជើងកូនចៅឡូចដែលនៅក្រោមឱវាទខ្លួន" ។ ក្នុងខ្លឹមសារនេះមានលក្ខណៈជា ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សង្គម និងសន្តិសុខសង្គមដែលអាចធ្វើឱ្យមហាជន ក្នុងបណ្តាញសង្គមមានការភាន់ច្រឡំ ស្អប់ខ្ពើម រើសអើង និងការប្រើប្រាស់ហិង្សាមកលើឈ្មោះ [redacted] ឆ័យណារ ភេទប្រុស អាយុ ៣៧ឆ្នាំ និងប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល និងថ្នាក់ដឹកនាំព្រមទាំងស្ថាប័ន ជាតិធ្ងន់ធ្ងរ។ ម្យ៉ាងវិញទៀតតាមចម្លើយរបស់ឈ្មោះ [redacted] ម៉ារី មិនបានបង្ហាញសារគំរាមហើយថាមានថ្នាក់ដឹកនាំក្រសួងការពារជាតិបញ្ជាឱ្យលុបចោលសារសម្លេងបង្ហោះចេញ។ ឈ្មោះអ៊ិត ម៉ារី នៅតែបន្តបង្ហោះសារចែកចាយ រូបភាពខាងលើជាបន្តបន្ទាប់។



Scanned with CamScanner

នៅអំឡុងខែមករា ឆ្នាំ២០២១ ឈ្មោះ [redacted] ម៉ារី ភេទស្រី អាយុ ៣៧ឆ្នាំ បានលួងលោមឈ្មោះ [redacted] សុផាត ភេទ ប្រុស ថាមានបងប្អូនណាចង់ចូលក្របខណ្ឌក្រសួងការពារជាតិ ព្រោះគាត់អាចរត់ការបាន និងធ្វើការនៅទីនោះស្រាប់, បើចង់ចូលអស់ចំនួន ៣២.០០០$ ចូលបានហើយៗបើមិនបានចូលឱ្យលុយវិញ, ពេលនោះឈ្មោះ [redacted] សុផាត បានទាក់ទងបងប្អូនរបស់គាត់ដើម្បីបញ្ចូលឈ្មោះក្នុងក្របខណ្ឌក្រសួងការពារជាតិតាមរយៈឈ្មោះ [redacted] ម៉ារី។ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០២៣ នៅចំណុចទីស្តីការក្រសួងការពារជាតិ រាជធានីភ្នំពេញ ឈ្មោះ [redacted] សុផាត បានយកលុយចំនួន ៣២.០០០$ ឱ្យទៅឈ្មោះ [redacted] ម៉ារី ដោយផ្ទាល់ដៃ ដោយឈ្មោះ [redacted] ម៉ារី អះអាងថាកុំភ័យនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ដឹងតែធ្លាក់ឈ្មោះហើយ, បើមិនបានទេប្អូនប្រគល់លុយគ្រប់ចំនួនវិញ។ លុះដល់ថ្ងៃកំណត់នៅមិនទាន់ឃើញធ្លាក់ឈ្មោះក៏ឈ្មោះ [redacted] សុផាត បានទាក់ទងឈ្មោះ [redacted] ម៉ារីៗ ប្រាប់ថាអត់អីទេបង ចាំប្រគល់លុយឱ្យវិញចាប់តាំងពីពេលនោះមកឈ្មោះ [redacted] ម៉ារី គេចវេសមិនបានប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] សុផាត វិញទេ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] ម៉ារី (អវត្តមាន)

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆ័យណា, ឈ្មោះ [redacted] សុផាត (អវត្តមាន)

- សាក្សីឈ្មោះ [redacted] ចំរើន, ឈ្មោះ [redacted] សោភ័ណ្ឌ, ឈ្មោះ [redacted] សាមឿន, [redacted] សុជាតិ, [redacted] សុទ្ធី, [redacted] មូហាំម៉ាត់, [redacted] សីហា (អវត្តមាន)

- មេធាវីការពារសិទ្ធិឱ្យជនជាបចោទឈ្មោះ [redacted] (វត្តមាន)

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ម៉ារី បានឆ្លើយនៅដំណាក់កាលស៊ើបសួរថា៖ រូបខ្លួនពិតជាបានទទួលលុយ ៣២.០០០$ ពិតប្រាកដមែន ដោយបានដកលុយ២០០$ឱ្យទៅឈ្មោះ [redacted] សុផាត ជាថ្នូរនាំមកបានពឹងខ្លួនពីករណីដាក់ក្មេងប្រុសម្នាក់ឱ្យចូលបម្រើការងារជោគជ័យ និងទី២ ដាក់ប្អូនថ្លៃឱ្យចូលក្របខណ្ឌវេជ្ជបណ្ឌិតនៅសាលាយោធាចោមចៅតែពេលដាក់ឯកសាររួចប្អូនរបស់ឈ្មោះ [redacted] សុផាត បានជាប់រៀនបូកនៅប្រទេសថៃ ឱ្យបានសុំដកខ្លួននិងបានសុំលុយពាក់កណ្តាលវិញ តែលុយខ្លួនបានយកទៅចាត់ចែងជាមួយមេឈ្មោះ [redacted] សុទ្ធីអស់ចំនួន៨.០០០$ និងនៅខ្លួនចំនួន៧.០០០$ ដោយខ្លួនបានចចារថាលក់ដីនៅប៉ោយប៉ែតដាច់សងលុយ ៧.០០០$វិញ។ ក្រោយមកឈ្មោះ [redacted] សុផាត ព្រមទទួលលុយ១.៧០០$ ពីឈ្មោះ [redacted] សុទ្ធី ដើម្បីបញ្ចប់រឿងបន្ទាប់មករូបខ្លួន ឈ្មោះ [redacted] សុផាត និងប្អូនរបស់ឈ្មោះ [redacted] សុផាត បានបង្កើត Messenger រួមគ្នាដើម្បីប្រើប្រាស់។ ដំបូងឡើយរូបខ្លួនមិនស្គាល់ឈ្មោះ [redacted] សុផាត ទេ តែមេខ្លួនបានឱ្យឈ្មោះ [redacted] សុផាត មកជួបខ្លួន និងបានប្រគល់ប្រាក់ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិកឱ្យខ្លួន។ ខ្លួនបានធ្វើកិច្ចសន្យាពីរផ្សេងគ្នា ទី១ ប្រាក់ ១៥.០០០ (មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ជាកិច្ចសន្យាបម្រើយោធា និងទី២ ប្រាក់ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក ជាកិច្ចសន្យាចូលក្របខណ្ឌវេជ្ជបណ្ឌិតសាលាពេទ្យយោធា។ ក្រោយមកឈ្មោះ [redacted] សុផាត បានឱ្យខ្លួនធ្វើលិខិតខ្ចីប្រាក់ថ្មីមួយផ្សេងទៀត ដើម្បីសរុបប្រាក់រួម ដែលខ្លួនបានខ្ចីដោយហែកកិច្ចសន្យាចាស់ចោល និងឱ្យមេ [redacted] សុទ្ធី ជាសាក្សីវិញ។ ចំពោះរូបខ្លួន សំណូមពរស្នើសុំវត្ថុតាង (ទូរស័ព្ទពីរគ្រឿងម៉ាកOPPO



Scanned with CamScanner

Find N2 ពណ៌មាស ចំនួន០១គ្រឿង និងម៉ាក OPPO Reno ពណ៌ខ្មៅ ចំនួន០១គ្រឿង) និងកុំឱ្យមានការឃុំខ្លួន ព្រោះរូបខ្លួនមានកូនអាយុ ១ខួប ៣ខែ គ្មានអ្នកមើលថែរទេ។

-តាមអំណានចម្លើយតទល់គ្នារវាងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផាត និងជនជាប់ចោទឈ្មោះ [redacted] ម៉ារី នៅដំណាក់កាលចៅក្រមស៊ើបសួរថា៖

ក-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផាត បានអះអាងថា៖ ឈ្មោះ [redacted] ម៉ារី មិនគោរពតាមពាក្យសន្យាខ្លួនក៏បានឱ្យឈ្មោះ [redacted] ម៉ារី ធ្វើកិច្ចសន្យាជាលើកទី២ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ ដើម្បីប្រគល់លុយឱ្យមកខ្លួនវិញ។ ចំពោះកិច្ចសន្យាទាំងពីរលើកនេះមិនមែនជាការខ្ចីលុយនោះទេ ដោយសារឈ្មោះ [redacted] ម៉ារី យកលុយ៣២.០០០$ យកទៅប្រើប្រាស់ ដើម្បីចូលក្របខណ្ឌមិនបានខ្លួនក៏ឱ្យឈ្មោះ [redacted] ម៉ារី បង្វែរទៅជាកិច្ចសន្យាខ្ចីប្រាក់វិញដើម្បីឱ្យឈ្មោះ [redacted] ម៉ារី សងប្រាក់វិញ ប៉ុន្តែឈ្មោះ [redacted] ម៉ារី មិនគោរពកិច្ចសន្យា និងបានប្ដឹងទៅនាយកដ្ឋានអធិការកិច្ចនៃក្រសួងការពារជាតិបានហៅឈ្មោះ [redacted] ម៉ារី ឱ្យធ្វើកំណត់ហេតុសាក្សីនៅនាយកដ្ឋាននៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង០៨:៣០នាទីព្រឹក។ ចំពោះចូលក្របខណ្ឌប្រាក់ ៣២.០០០$ នោះគឺស្នើសុំបញ្ចូលតែឈ្មោះម្នាក់នោះទេមិនមែនពីរនាក់ដូចការលើកឡើងរបស់ឈ្មោះ [redacted] ម៉ារី ទេ។

ខ-ជនជាប់ចោទឈ្មោះ [redacted] ម៉ារី បានឆ្លើយថា៖ ចំពោះប្រាក់ ៣២.០០០$ ដែលឈ្មោះ [redacted] សុផាត ប្រគល់ឱ្យខ្លួនចូលក្របខណ្ឌមានពីរនាក់ គឺមួយចូលក្របខណ្ឌយោធា និងម្នាក់ទៀតចូលក្របខណ្ឌគុកទ័រ។ តែក្រោយមកមានបញ្ហាឈ្មោះរៀម សុផាត បានឱ្យខ្លួនធ្វើកិច្ចសន្យាខ្ចីលុយវិញចំនួន ៣២.០០០$ ដោយខ្លួននៅជំពាក់ឈ្មោះ [redacted] សុផាត ចំនួន ៧.០០០$ បន្ទាប់ពីចរចាគ្នារួច។ ចំពោះការចូលក្របខណ្ឌនោះមានមនុស្សពីរនាក់មិនមែនម្នាក់ដូចការលើកឡើងរបស់ ឈ្មោះ [redacted] សុផាត ទេ, កិច្ចសន្យាទី១ មិនមានវត្តមានឈ្មោះ [redacted] សុទ្ធី ចូលរួមទេ និងលើកទី២ រូបខ្លួនបានចូលរួមធ្វើជាមួយដែរ ដោយឈ្មោះ [redacted] សុផាត បានយល់ព្រមយកប្រាក់ចំនួន១.៧០០$ ដើម្បីបញ្ចប់រឿងជាមួយឈ្មោះ [redacted] សុទ្ធី, នៅឡើយតែលុយរបស់ខ្លួនប៉ុណ្ណោះ មិនទាន់ដោះស្រាយរួច។

-តាមអំណានចម្លើយតទល់គ្នារវាង មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆ័យណារ៉, ជនជាប់ចោទឈ្មោះ [redacted] ម៉ារី និងសាក្សីឈ្មោះ [redacted] សីហា៖

ក-មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆ័យណារ៉ បានអះអាងថា៖ កូនក្ដីខ្លួនបានទទួលការតឹងពាក់ពីចិនបានតេទៅឈ្មោះ [redacted] ម៉ារី និយាយរឿងPassport របស់ចិនបានដកឱ្យគេវិញ ហើយឈ្មោះ [redacted] ឆ័យណារ៉ បានតេទៅប៉ូលីសដែលជា សាក្សីម្នាក់ទៀតសួរថា Passport របស់ចិននោះនៅប៉ូលីស ឬទាហ៊ាន។ បន្ទាប់ពីសួរនាំទើបដឹងថាPassport ប្រគល់ ឈ្មោះ [redacted] សីហា ដោយ ឈ្មោះ [redacted] សីហា បានប្រគល់មិត្តភ័ក្ត្រខ្មើយយកទៅបន្តVisa។ ក្រោយមកគេដឹងថាPassport របស់ចិនត្រូវបានអគ្គនាយកអន្តោប្រវេសន៍ប្ដឹង ក៏ឈ្មោះ [redacted] ម៉ារី បានតេទៅកូនក្ដីខ្លួនៗក៏សម្របសម្រួលជាមួយឈ្មោះ [redacted] ម៉ារី ឱ្យយកលុយមកឱ្យចិនវិញ, តែបើកូនក្ដីខ្លួនទៅកាងរឿងឱ្យអ្នកណានោះគឺមិនមានទេ ។ តាមពិត Passport របស់ ចិន មិនមែនតុលាការដកហូតទេគឺជាប់គាំងនៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ជាដកហូតដោយសារតែខុសច្បាប់។ ប៉ុន្តែចិនសុំតែPassportមកវិញទេ ហើយឈ្មោះ [redacted] ម៉ារី តែងតែតេទៅឈ្មោះ [redacted] ឆ័យណារ៉ និងរាល់ការគេម្ដងៗតែងតែយករូបថតរបស់កូនក្ដីខ្លួន



Scanned with CamScanner

មកបង្ហោះលាភពណ៌ជាហ្វូរហែរ។ ក្រោយពីកូនក្តីរបស់ខ្លួនប្តឹងមកតុលាការឈ្មោះ [redacted] ម៉ារី ក៏បានបង្ហោះទៀតរៀងរាល់ពេល និងប្រឌិតហេតុការណ៍ផ្សេងៗ។ ដោយឡែកកូនក្តីខ្លួនមិនដែលកាងឱ្យឈ្មោះ [redacted] សីហា ទេ ឬក៏ឱ្យជំនួយការទៅគំរាមកំហែងឈ្មោះ [redacted] ម៉ារី ទេ។ កូនក្តីខ្លួនមានសារឆ្លើយឆ្លងគ្នារវាងកូនក្តីខ្លួន និងឈ្មោះ [redacted] ម៉ារី។

ខ.សាក្សីឈ្មោះ [redacted] សីហា បានឆ្លើយថា៖ រូបខ្លួនមានមុខនាទីប៉ូលីសទេសចរនៅប៉ោយប៉ែតខេត្តបន្ទាយមានជ័យ។ ខ្លួនបានពឹងប៉ូលីសម្នាក់ឱ្យជួយធ្វើ Passport ឱ្យចិន ហើយប៉ូលីសនោះបានឱ្យខ្លួនសួរនាំ និងទាក់ទងឈ្មោះ [redacted] ម៉ារី។ ឈ្មោះ [redacted] ម៉ារី បានទារលុយពីចិនចំនួន ៤.៨00$ យកទៅជួបជំទាវឈ្មោះ [redacted] ចាន់ធឿន។ ចិនបានសួរនាំខ្លួន ហើយខ្លួនបានសួរទៅឈ្មោះ [redacted] ម៉ារី បានទារលុយ ៣៥.000$ទៀត ទើបបាន Passport មកវិញ ហើយចិនមិនយល់ព្រមវិញ។ ខ្លួនមិនដែលគំរាម និងថាប្តឹងឈ្មោះ [redacted] ម៉ារី នោះទេ, មានតែឈ្មោះ [redacted] ម៉ារី ទេ គំរាមប្តឹងខ្លួនទៅប្រធានអង្គភាពរបស់ខ្លួនថាខ្លួនយកលុយ ៣៥.000$ ពីចិនរត់ការធ្វើPassport ពេលនោះឈ្មោះ [redacted] ម៉ារី ថាខ្លួនយកប្រធានអង្គភាពមកកាង ហើយឈ្មោះ [redacted] ម៉ារី បានទៅរករឿងប្រធានអង្គភាពខ្លួននៅភ្នំពេញ ហើយខ្លួនបានធ្វើរបាយការណ៍ជូនមេ។ ឈ្មោះ [redacted] ម៉ារី ថាខ្លួនបានទៅពឹងឈ្មោះ [redacted]ំរើន នៅពីក្រោយខ្នង ឈ្មោះ [redacted] ចំរើន បានហៅខ្លួនមកសួរនាំខ្លួនរៀបរាប់ដំណើររឿងជូនគាត់ ហើយឈ្មោះ [redacted] ម៉ារី និងយករូបខ្លួនមកPost facebook និងបានចោទរូបខ្លួនជាហ្វូរហែររហូតយកឈ្មោះថ្នាក់ដឹកនាំមកលាភពណ៌ផង រូបខ្លួនបានសួរទៅចិនរឿងលុយ៣៥.000$ ចិនគាត់ព្រមឱ្យបើធ្វើPassportបានរួច យកមកឱ្យគាត់នៅប៉ោយប៉ែតក៏ឈ្មោះ [redacted] ម៉ារី ថាបើមិនមានលុយឱ្យមុនទៅយកនៅកន្លែងធ្វើPassportនោះទេ គាត់មិនធ្វើឱ្យនោះទេ ហើយខ្លួនបានសួរចិន ចិនថាមិនទៅយកទេ។ ខ្លួនបានប្រាប់ទៅឈ្មោះ [redacted] ម៉ារី ថាធ្វើកិច្ចសន្យាខ្ចីប្រាក់ទៅរវាងខ្លួនជាមួយឈ្មោះ [redacted] ម៉ារី ខ្ចីប្រាក់៣២.000$ ដើម្បីយកPassport (តែមិនបានធ្វើកិច្ចសន្យា)។ ក្រោយមកឈ្មោះ [redacted] ម៉ារី ក្រឡាស់សម្តីបើមិនឱ្យលុយមុនមិនឱ្យនោះទេ, បន្ទាប់មកឈ្មោះ [redacted] ម៉ារី ប្តឹងទាមទារប្រាក់៣៥.000$ ។

គ. ជនជាប់ចោទឈ្មោះ [redacted] ម៉ារី អះអាងថា៖ ឈ្មោះ [redacted] សីហា បានយក Passport របស់ចិនបន្តVisa មកពឹងមិត្តភ័ក្ត្ររបស់ខ្លួន ហើយមិត្តភ័ក្ត្រខ្លួនមកពឹងខ្លួនឱ្យជួយបន្ត។ ខ្លួនក៏ដឹងថាPassport មានបញ្ហាដោយសារបោះត្រាឆ្លងដែនខុសច្បាប់ ដោយឆ្លងដែនតាមកប៉ាល់ខុសច្បាប់។ ចំពោះ Passport ធ្វើមិនកើតនោះទេត្រូវបានតុលាការរាជធានីភ្នំពេញដកហូតវិញ ទេនៅជាន់ទី១ បន្ទប់អក្សរ "ខ" ខ្លួនក៏បានចូលជួបថ្កាយពីរ ហើយតុលាការបានចរចាជាមួយនឹងបានទារប្រាក់ ៥0.000$ ដោយឱ្យចិនជួបផ្ទាល់តែចិនមិនជួបខ្លាចគេចាប់។ ពេលនោះចិនបានពឹងឈ្មោះ សីហា ឱ្យមកយកជំនួសតែឈ្មោះ សីហា បានឱ្យខ្លួនទៅយកចាំឱ្យលុយតាមក្រោយ។ ក្រោយមកខ្លួនបានទាក់ទងឈ្មោះ សីហា ថាលុយសល់ ៥.000$នោះទេ បើមិនយកប៉ុណ្ណឹងយកPassport ទៅដាំទឹកផឹកទៅខ្លួននឹងបានទៅជួបប្រធានអង្គភាពរបស់ឈ្មោះ សីហា ។ ដល់ថ្ងៃដែលណាត់យក Passport នៅអគ្គស្នងការឈ្មោះ សីហា គេចវេះរហូត។ អគ្គស្នងការបានទម្លាក់កំហុសមកខ្លួន ខ្លួនក៏ដឹងថាឈ្មោះ សីហាបានយកលុយពីចិនរួចហើយ តែមិនព្រមយលលុយប្រគល់ឱ្យខ្លួន ខ្លួនក៏ចេញលុយជំនួសចិនចំនួន៣៥.000$ រួចខ្លួនបានទាក់ទងឈ្មោះ សីហា ឱ្យចិនមកយក Passport នៅអគ្គស្នងការ ដល់ថ្ងៃណាត់ក៏មិនឃើញមក។ ខ្លួនបានប្រគល់Passportទៅ



Scanned with CamScanner

អគ្គស្នងការវិញ។ ចំពោះឈ្មោះ [redacted] ឆ័យណារ៍ ធ្លាប់បានខលមកខ្លួនថាគាត់បានពឹងពាក់ឈ្មោះ [redacted] ចំរើន ជួយអន្តរាគមន៍កូនចៅគាត់ម្នាក់នៅប៉ោយប៉ែត ដែលគាត់ជាអ្នកជំពាក់លុយរបស់ខ្លួន និងសុំឲ្យខ្លួនដកពាក្យបណ្តឹងវិញ ខ្លួនបានគេទៅមេៗថា មានលេខមួយបានតេមកខ្លួនគេថាជាកូនថ្នាក់ដឹកនាំឈ្មោះ [redacted] ផាត ហើយមេខ្លួនថា មិនស្គាល់នោះទេ។

-តាមអំណានចម្លើយតទល់រវាងសាក្សីឈ្មោះ [redacted] មូហាម៉ាត់ និងជនជាប់ចោទឈ្មោះ [redacted] ម៉ារី៖

ក. សាក្សីឈ្មោះ [redacted] មូហាំម៉ាត់ អះអាងថា៖ ឈ្មោះ [redacted] ម៉ារី បានតេទូរស័ព្ទមកខ្លួនដោយនិយាយរឿងធ្វើPassport របស់ចិន ប្រាប់ខ្លួនដោយនិយាយផ្តេសផ្តាស ខ្លួនចេះតែស្តាប់ទៅ ខ្លួនក៏ប្រាប់ទៅវិញថាខ្លួនមិនដឹងរឿងអ្វីនោះទេ។ ហើយឈ្មោះ [redacted] ម៉ារី ថាឈ្មោះ សីហា បានជំពាក់លុយគាត់ចំនួន៣.៥០០០$។ ប្រហែល ០១ខែ ស្រាប់តែឈ្មោះ [redacted] ម៉ារី បានបង្ហោះរូបខ្លួន និងឈ្មោះ សីហា តាមបណ្តាញ Facebook ខ្លួនក៏មិនបានរករឿងដែរ ។ ក្រោយមកខាងអាវុធហត្ថ បានប្រាប់ខ្លួនថា គេប្តឹងខ្លួនពីបទតេគំរាមកំហែងឈ្មោះ [redacted] ម៉ារី ហើយថារូបខ្លួនជាកូនចៅរបស់ឈ្មោះ [redacted] ឆ័យណារ៍។ កាលណោះរូបខ្លួនតេទៅឈ្មោះ [redacted] ម៉ារី តែម្តងគត់នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ ម៉ោង ០៩ព្រឹក ហើយខ្លួនមិនដែលនិយាយជាមួយឈ្មោះ [redacted] ម៉ារី ទាក់ទងការដកពាក្យបណ្តឹងឈ្មោះ សីហា នោះទេ។

ខ.ជនជាប់ចោទឈ្មោះ [redacted] ម៉ារី បានឆ្លើយថា៖ រូបខ្លួនស្នើសុំឱ្យតុលាការស្រាវជ្រាវរវាងខ្លួន និងឈ្មោះ [redacted] មូហាំម៉ាត់ ជាមួយលេខទូរស័ព្ទ ០៨៨៥ ៥៨៨៨៤៤ ជាមួយលេខ ០៩៧៣ ៦០៩ ៦៦៦ ដោយនិយាយសុំឱ្យរូបខ្លួនដកពាក្យបណ្តឹងឈប់ប្តឹងឈ្មោះ សីហា កាលនោះពីថ្ងៃទី០៩ ដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ ពេលទូរស័ព្ទម្តងៗ រូបខ្លួនតែងរាយការណ៍ជូនមេឈ្មោះ [redacted] សាមឿន។ រូបខ្លួនសុំឱ្យតុលាការកោះហៅសាក្សីឈ្មោះ [redacted] ចំរើន ,ឈ្មោះ [redacted] សុជាតិ, ឈ្មោះ [redacted] សុទ្ធី, ឈ្មោះ [redacted] សាមឿន និងឈ្មោះ [redacted] សោភ័ណ្ឌ បានដឹងឮរឿងនេះ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ឆ្លងតាមការដេញដោលនៅក្នុងសវនាការ តាមអង្គហេតុ អំណានចម្លើយជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណី , ការអះអាងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងសាក្សី តំណាងអយ្យការរក្សាការចោទប្រកាន់នៅដដែល និងស្នើសុំឱ្យតុលាការពិចារណាលើការបន្ធូរបន្ថយទោសដល់ជនជាប់ចោទ និងដកទុកវត្ថុតាងទូរស័ព្ទ២គ្រឿងរបស់ជនជាប់ចោទ ដោយជនជាប់ចោទនេះតែបង្ហោះផ្តេសផ្តាសព្រោះក្នុងទូរស័ព្ទជនជាប់ចោទមានផ្ទុកអ្វីច្រើន ប៉ុន្តែស្នើសុំឱ្យតុលាការពិនិត្យ និងកត់សម្គាល់លើបុគ្គលិកលក្ខណៈ ឥរិយាបទ របស់ជនជាប់ចោទផងដែរ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ចំពោះបទល្មើស **“បរិហារកេរ្តិ៍ជាសាធារណៈ”** បើពិនិត្យលើសំណុំរឿងមុនឈានដល់ការប្រព្រឹត្តបទល្មើសបរិហារកេរ្តិ៍ជាសាធារណៈ គឺកូនក្តីខ្លួនមានជម្លោះជាមួយនិងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆ័យណារ៍ ដោយមានការឈ្លោះប្រកែកគ្នា រហូតមានការបង្ហោះរូបភាពលើបណ្តាញសង្គម Facebook រហូតដល់មានពាក្យបណ្តឹងប្តឹងកូនក្តីខ្លួនពីបទ បរិហារកេរ្តិ៍ជាសាធារណៈនេះ។ ដូច្នេះ នៅក្នុងចំណុចនេះ គឺកូនក្តីខ្លួនស្នើសុំឱ្យចៅក្រមជំនុំជម្រះមេត្តាពិចារណាបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនពាក់ព័ន្ធនិងបទល្មើស **“បរិហារកេរ្តិ៍ជាសាធារណៈ”** ដោយសារគាត់មាន



Scanned with CamScanner

កំហឹងមួយពេលទើបបានជាគាត់បង្ហោះរូបភាពលើបណ្តាញសង្គម Facebook ហើយមកដល់ពេលនេះ កូនក្តីខ្លួនក៏បានដឹងពីកំហុសរបស់ខ្លួនផងដែរ។ ចំពោះករណី "**ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍**" គឺកូនក្តីខ្ញុំបាទមិនបានធ្វើការញុះញង់ឱ្យធ្វើអំពើហិង្សា ឬធ្វើឱ្យមានភាពវឹកវរខ្លាំងនៅក្នុងសង្គមដែលជាព្យសនកម្មអ្វីមួយក្នុងសង្គមឡើយ ហេតុដូច្នេះ កូនក្តីខ្លួនមិនមានចេតនាក្នុងការប្រព្រឹត្តបទល្មើសនេះទេ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ "**ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍**" ជាអាទិ៍។ រីឯបទល្មើសមួយទៀតបទ"**ញុះញង់ឱ្យមានការរើសអើង និងស្អប់ខ្ពើមថ្នាក់ដឹកនាំ និងស្ថាប័នក្រសួងការពារជាតិ**" នៅក្នុងករណីនេះដែរកូនក្តីខ្លួនគាត់បានដឹងពីកំហុសរបស់ខ្លួន ហើយបានធ្វើលិខិតសុំទោសទៅក្រសួងការពារជាតិរួចរាល់ហើយ ហើយក្រសួងការពារជាតិក៏គាត់មិនបានប្រកាន់ទោសអ្វីសដំណើរអ្វីដែរ ថែមទាំងបានចាត់មេធាវីតំណាងក្រសួងការពារជាតិដើម្បីមកការពារជូនគាត់មកធ្វើនីតិវិធីផ្សេងៗ ក៏ដូចជាការស្នើសុំក្រៅឃុំផងដែរ ក៏ដូចជាមានលិខិតផ្សេងជាបន្តបន្ទាប់ដាក់ចូលនៅក្នុងសំណុំរឿងរួចហើយដែរ។ ដូច្នេះ ពាក់ព័ន្ធជាមួយបទល្មើសនេះផងដែរ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំឱ្យកូនក្តីខ្លួនរួចផុតពីបទចោទផងដែរ។ រីឯកបទល្មើសចុងក្រោយ បទល្មើស "ឆបោក" នៅក្នុងសំណុំរឿងនេះ ដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងកូនក្តីខ្លួនថាបានឆបោកប្រាក់របស់ខ្លួនចំនួន ៣២.០០០ (បីម៉ឺនពីរពាន់)ដុល្លារអាមេរិក តែជាក់ស្តែងកូនក្តីខ្លួនបានទទួលស្គាល់នៅក្នុងនីតិវិធីតទល់តែ ៧.០០០ (ប្រាំពីរពាន់)ដុល្លារតែប៉ុណ្ណោះ ចំណែកប្រាក់ផ្សេងៗទៀតគាត់បានអះអាងថា គាត់បានយកទៅរត់ការជួយទៅឈ្មោះ [redacted] សុផាត រួចរាល់ ហើយក្មួយ [redacted] សុផាត ក៏បានចូលក្នុងក្របខណ្ឌយោធារួចរាល់ហើយដែរ។ រីឯប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់)ដុល្លារ ទៀតគាត់ក៏មិនត្រូវទូទាត់ជាមួយឈ្មោះ [redacted] សុផាត នេះដែរ គាត់ត្រូវទូទាត់ជាមួយនិងក្មួយរបស់ឈ្មោះ [redacted] សុផាត តែប៉ុណ្ណោះ ហេតុដូច្នេះ ចំណុចនេះ ស្នើសុំមេត្តាចៅក្រមពិចារណាបន្ធូរបន្ថយទោសជូនកូនក្តីខ្លួនផង។ ជាចុងក្រោយកូនក្តីខ្លួនស្នើសុំវត្ថុចាប់យករួមមាន ទូរស័ព្ទដៃចំនួន ០២គ្រឿង ដែលបានដកហូតពីកូនក្តីខ្លួន។

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ារី
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាង ឯកសារទាំងអស់ក្នុងសំណុំរឿង
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា:

១-នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ រហូតដល់មានបណ្តឹង "**បរិហារកេរ្តិ៍ជាសាធារណៈ, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍, ញុះញង់ឱ្យមានការរើសអើង និងស្អប់ខ្ពើមថ្នាក់ដឹកនាំ និងស្ថាប័នក្រសួងការពារជាតិ**" ប្រព្រឹត្តនៅតាមបណ្តាញFacebook name [redacted] និងTelegram និងកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ មានករណីបទ "**ឆបោក**" ប្រព្រឹត្តនៅទីស្តីការក្រសួងការពារជាតិ ស្ថិតនៅខណ្ឌមិត្តភាព រាជធានីភ្នំពេញ ប្រាកដមែន។



Scanned with CamScanner

២-តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៦២/២០២៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការខេត្តកំពង់ធំ និងដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៣០០៤/២០២៣ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ធំ បានសម្រេចចោទប្រកាន់លើឈ្មោះ [redacted] ម៉ារី ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ មានសាវតារជាតិដូចខាងលើ ពីបទ "**បរិហាកេរ្តិ៍ជាសាធារណៈ, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍, ញុះញង់ឱ្យមានការរើសអើង និងស្អប់ខ្ពើមថ្នាក់ដឹកនាំ និងស្ថាប័នក្រសួងការពារជាតិ**" ប្រព្រឹត្តនៅតាមបណ្តាញFacebook name [redacted] Ka និងTelegram កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ រហូតដល់បច្ចុប្បន្ន **តាមបញ្ញត្តិមាត្រា៤៩៤, មាត្រា៤៩៥, មាត្រា ៣០៥ និងមាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** និងពីបទ "**ឆបោក**" ប្រព្រឹត្តនៅទីស្តីការក្រសួងការពារជាតិ ស្ថិតនៅសង្កាត់មិត្តភាព ខណ្ឌ០៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ **តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ**។

៣-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ារី បានឆ្លើយថា៖ ចំពោះករណីដែលឈ្មោះ [redacted] សុផាត ប្តឹងខ្លួនបទល្មើស "**ឆបោក**" នៅក្នុងសំណុំរឿងនេះប្រាក់ចំនួន ៣២.០០០ (បីម៉ឺនពីរពាន់)ដុល្លារអាមេរិក ខ្លួនទទួលស្គាល់នៅក្នុងនីតិវិធីតទល់តែ ៧.០០០ (ប្រាំពីរពាន់)ដុល្លារតែប៉ុណ្ណោះ ចំណែកប្រាក់ផ្សេងៗទៀត ខ្លួនបានយកទៅរត់ការជួយទៅឈ្មោះ [redacted] សុផាត រួចរាល់ ហើយក្មួយ [redacted] សុផាត ក៏បានចូលក្នុងក្របខណ្ឌយោធារួចរាល់ហើយដែរ។ រីឯប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់)ដុល្លារ ទៀតគាត់ក៏មិនត្រូវទូទាត់ជាមួយឈ្មោះ [redacted] សុផាត នេះដែរ គាត់ត្រូវទូទាត់ជាមួយនិងក្មួយរបស់ឈ្មោះ [redacted] សុផាត តែប៉ុណ្ណោះ។ បើផ្អែកលើតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ារី បានបង្ហាញថា ខ្លួនពិតជាមានទំនាក់ទំនងជាមួយដើមបណ្តឹងឈ្មោះ [redacted] សុផាត ក្នុងការរត់ការឱ្យប្អូនឈ្មោះ [redacted] សុផាត ដោយបានប្រគល់ប្រាក់ឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ារី ចំនួន ៣២.០០០ (បីម៉ឺនពីរពាន់)ដុល្លារអាមេរិក នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រោយទទួលបានប្រាក់ឈ្មោះ [redacted] ម៉ារី មិនបានបំពេញកាតព្វកិច្ចដូចការសន្យាទេ ហើយថែមទាំងមិនបានប្រគល់ប្រាក់ឱ្យដើមបណ្តឹងវិញ ទើបដើមបណ្តឹងបង្វែរសាច់រឿងទៅជាការខ្ចីប្រាក់រវាងខ្លួន និងជនជាប់ចោទឈ្មោះ [redacted] ម៉ារី ដូចមានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ និងកិច្ចសន្យាចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០២១ រវាងដើមបណ្តឹងឈ្មោះ [redacted] សុផាត និងជនជាប់ចោទ [redacted] ម៉ារី ជាភស្តុតាងដែលដាក់ជូនតុលាការពិនិត្យ។ ទង្វើរនេះ ជនជាប់ចោទមានចេតនាទុច្ចរិតឱ្យដើមបណ្តឹងប្រគល់ប្រាក់ឱ្យខ្លួនប៉ុណ្ណោះពេលបានប្រាក់រួចហើយ ពុំធ្វើការឱ្យជនរងគ្រោះ ហើយលុយក៏ពុំសងជនរងគ្រោះវិញដែរ។

៤-ផ្អែកតាមភស្តុតាងដែលដាក់ជូនតុលាការពិនិត្យ និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ារី បានទទួលស្គាល់ថាខ្លួនពិតជាបានបង្ហោះនូវពាក្យពេចន៍នៅក្នុងបណ្តាញសង្គម facebook ដែលមានខ្លឹមសារថា "ថ្ងៃមុនទៅប៉ោយប៉ែតប្តឹងប៉ូលីសចរាចរណ៍រឿងបោកលុយខ្លួន ចំនួន៣៥.០០០$ ខណៈពេលនោះមានអ្នកចេញមុខតតាំងនាមជាកូនថ្នាក់ដឹកនាំ [redacted] ផាត និងជាជំនួយការកូនថ្នាក់ដឹកនាំធំទី១ម្នាក់ទៀតមកគំរាមខ្លួនឱ្យដកពាក្យបណ្តឹងព្រោះគេទទួលការពឹងពាក់ឱ្យជួយសម្រួលដាច់ខាតឱ្យខ្លួនដកពាក្យបណ្តឹងជាបន្ទាន់ ស្តាប់ឮហើយរូបខ្លួនភ័យញ័រជើងហ្នឹងសូមជម្រាបជូនអស់លោកជ្រាប បើមិនទាន់សងលុយខ្លួនទេ, កុំសង្ឃឹមថា ខ្លួនបញ្ចប់រឿងហើយដកពាក្យបណ្តឹងអី



Scanned with CamScanner

ត្រឹមស្ត្រីមេម៉ាយម្នាក់គ្មានខ្នងបង្អែក គ្មានខ្សែអ្នកធំចាំជួយដូចអ្នកទេ, តែខ្លួនត្រូវប្តឹងទាមទាររកខុសត្រូវសខ្មៅឱ្យខ្លួនឯងបានយុត្តិធម៌វិញ, ខ្លួនមិនធ្លាប់ខ្លាចអំណាចបុណ្យស័ក្តអ្នកណាទេ បើខ្លួនមិនខុស ....សង្ឃឹមថាថ្នាក់ដឹកនាំធ្វើជាគំរូល្អ កុំកាន់ជើងកូនចៅដែលនៅក្រោមឱវាទខ្លួន" ដែលខ្លឹមសារទាំងនេះមានលក្ខណៈជា ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សង្គម និងសន្តិសុខសង្គមដែលអាចធ្វើឱ្យមហាជន ក្នុងបណ្តាញសង្គមមានការភាន់ច្រឡំ ស្អប់ខ្ពើម រើសអើង និងការប្រើប្រាស់ហិង្សាមកលើឈ្មោះ [redacted] ឆ័យណារ៉ា ភេទប្រុស អាយុ ៣៧ឆ្នាំ និងប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល និងថ្នាក់ដឹកនាំព្រមទាំងស្ថាប័នជាតិធ្ងន់ធ្ងរ ស៊ីសង្វាក់ទៅនិងចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] ឆ័យណារ៉ា ថាខ្លួនមិនបានទំនាក់ទំនងជាមួយឈ្មោះ [redacted] ម៉ារី ឡើយ ហើយ [redacted] ម៉ារី មកបង្ហោះអ្វីឱ្យខ្លួនអាម៉ាស និងខូចឈ្មោះ ថ្នាក់ដឹកនាំ និងស្អប់ខ្ពើមខ្លួន អាចឱ្យតុលាការពិចារណាបាន។

៥-តាមតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផាត បានបញ្ជាក់ថា ខ្លួនមានទំនាក់ទំនងជាមួយឈ្មោះ [redacted] ម៉ារី ជាយោធាបម្រើការងារនៅអគ្គលេខាធិកាដ្ឋាននៃក្រសួងការពារជាតិរាជធានីភ្នំពេញ ដោយខ្លួនបានពឹងឱ្យឈ្មោះ [redacted] ម៉ារី រត់ការឱ្យប្អូនខ្លួនចូលបម្រើការងារនៅក្នុងក្របខណ្ឌពេទ្យយោធា ក្នុងតម្លៃ ៣២.០០០$ តែឈ្មោះ [redacted] ម៉ារី មិនបានបំពេញកាតព្វកិច្ចក្នុងការរត់ការ ហើយក៏មិនបានឱ្យប្រាក់ខ្លួនវិញដែរ រហូតដល់មានការបង្ខំរសាច់រឿងទៅជាឈ្មោះ [redacted] ម៉ារី ជំពាក់ប្រាក់វិញ ដូចមានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ និងកិច្ចសន្យាចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០២១ តែឈ្មោះ [redacted] ម៉ារី នៅតែមិនគោរពកិច្ចសន្យាសងប្រាក់ខ្លួនវិញទៀត និងតែងតែគេចវេសរហូត អាចឱ្យតុលាការជឿបាន។

៦-តាមបញ្ញត្តិមាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ អំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជន នូវ: ១-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ, ២-ការផ្តត់ផ្គង់សេវា, ៣-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច ជាអំពើ "**ឆបោក**" ដោយឈ្មោះ [redacted] ម៉ារី បានធ្វើការបោកបញ្ឆោតឈ្មោះ [redacted] សុផាត ដោយសន្យានិងរត់ការឈ្មោះចូលក្របខណ្ឌឱ្យប្អូន [redacted] សុផាត តែខ្លួនមិនបានបំពេញកាតព្វកិច្ចក្នុងការរត់ការនោះទេ ថែមទាំងមិនបានប្រគល់ប្រាក់ឱ្យសមីខ្លួនវិញ ជនជាប់ចោទមានចេតនាទុច្ចរិតប្រាកដមែន។

៧-តាមបញ្ញត្តិមាត្រា៤៩៤, មាត្រា៤៩៥, មាត្រា ៣០៥ និងមាត្រា៤៩៦ បានបញ្ញត្តិពីបទ "**បរិហាកេរ្តិ៍ជាសាធារណៈ, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍, ញុះញង់ឱ្យមានការរើសអើង និងស្អប់ខ្ពើមថ្នាក់ដឹកនាំ និងស្ថាប័នក្រសួងការពារជាតិ**" ដោយជនជាប់ចោទឈ្មោះ [redacted] ម៉ារី បានបង្ហោះខ្លឹមសារនៅក្នុងបណ្តាញសង្គម Facebook ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សង្គម និងសន្តិសុខសង្គមដែលអាចធ្វើឱ្យមហាជន ក្នុងបណ្តាញសង្គមមានការភាន់ច្រឡំ ស្អប់ខ្ពើម រើសអើង និងការប្រើប្រាស់ហិង្សាមកលើឈ្មោះ [redacted] ឆ័យណារ៉ា ភេទប្រុស អាយុ ៣៧ឆ្នាំ និងប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល និងថ្នាក់ដឹកនាំព្រមទាំង ស្ថាប័នជាតិធ្ងន់ធ្ងរ អាចឱ្យតុលាការពិចារណាបាន។



Scanned with CamScanner

៨-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ារី ភេទស្រី អាយុ ៣៧ឆ្នាំ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ពីបទ **"បរិហាកេរ្តិ៍ជាសាធារណៈ, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍, ញុះញង់ឱ្យមានការរើសអើង និងស្អប់ខ្ពើមថ្នាក់ដឹកនាំ និងស្ថាប័នក្រសួងការពារជាតិ"** ប្រព្រឹត្តនៅតាមបណ្តាញFacebook name [redacted] Ka និងTelegram កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ រហូតដល់មានបណ្តឹង **តាមបញ្ញត្តិមាត្រា៤៩៤, មាត្រា៤៩៥, មាត្រា ៣០៥ និងមាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** និងពីបទ **"ឆបោក"** ប្រព្រឹត្តនៅទីស្តីការក្រសួងការពារជាតិ ស្ថិតនៅសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ **តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ** ទោះមានកិច្ចសន្យាខ្ចីប្រាក់ក៏ដោយក៏កិច្ចសន្យានេះធ្វើក្រោយទង្វើរបស់ជនជាប់ចោទបានប្រព្រឹត្តរួចរាល់ហើយ។ ជនជាប់ចោទជានីតិជន ពេលប្រព្រឹត្តមានស្មារតី ដឹងខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួន។

៩-ជនជាប់ចោទឈ្មោះ [redacted] ម៉ារី បានបំពានទៅនឹង **តាមបញ្ញត្តិមាត្រា៤៩៤, មាត្រា៤៩៥, មាត្រា ៣០៥ និងមាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ និងមាត្រា ៣៧៧, មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។**

១០-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ារី បានធ្វើឱ្យប៉ះពាល់កិត្តិយស សេចក្តីថ្លៃថ្នូរ ដល់របៀបរៀបរយសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដែលអំពើនេះត្រូវបានច្បាប់ការពារយ៉ាងតឹងរ៉ឹងហើយនៅតែប្រព្រឹត្តទៀត។

១១-ឆ្លងតាមការសួរដេញដោលនៅក្នុងសវនាការតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន រក្សាការចោទប្រកាន់នៅដដែល និងស្នើសុំឱ្យតុលាការពិចារណាលើការបន្ធូរបន្ថយទោសដល់ជនជាប់ចោទ ព្រមទាំងស្នើសុំឱ្យតុលាការពិនិត្យ និងកត់សម្គាល់លើបុគ្គលិកលក្ខណៈ ឥរិយាបទរបស់ជនជាប់ចោទ ក្នុងការផ្តន្ទាទោសផងដែរ ដើម្បីឱ្យជនជាប់ចោទ អប់រំ និងកែប្រែខ្លួនជាពលរដ្ឋល្អក្នុងសង្គម និងសុំឱ្យតុលាការដកហូតវត្ថុតាងទូរស័ព្ទរបស់ជនជាប់ចោទអាចយកទៅប្រើប្រាស់ធ្វើអ្វីផ្សេងទៀតដោយនៅក្នុងទូរស័ព្ទមានអ្វីផ្សេងទៀតមិនសមរម្យច្រើន អាចឱ្យតុលាការពិចារណាបាន។

១២-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យតុលាការបន្ថយបន្ធូរទោសឱ្យកូនក្តីខ្លួនលើបទល្មើស **"ឆបោក"** បទល្មើស **"បរិហាកេរ្តិ៍ជាសាធារណៈ ញុះញង់ឱ្យមានការរើសអើង និងស្អប់ខ្ពើមថ្នាក់ដឹកនាំ និងស្ថាប័នក្រសួងការពារជាតិ"** ដោយលើកមូលហេតុថា កូនក្តីខ្លួនគាត់បានដឹងពីកំហុសរបស់ខ្លួន ហើយបានធ្វើលិខិតសុំទោសទៅក្រសួងការពារជាតិរួចរាល់ហើយ ហើយក្រសួងការពារជាតិក៏គាត់មិនបានប្រកាន់ទោស អ្វីសដំណើរអ្វីដែរ អាចឱ្យតុលាការពិចារណាបាន។ ចំពោះបទល្មើស **"ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍"** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានស្នើសុំឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ ដោយលើកមូលហេតុថាគឺកូនក្តីបាទមិនបានធ្វើការញុះញង់ឱ្យធ្វើអំពើហិង្សា ឬធ្វើឱ្យមានភាព វឹកវរខ្លាំងនៅក្នុងសង្គមដែលជាព្យសនកម្មអ្វីមួយក្នុងសង្គមឡើយ កូនក្តីខ្លួនមិនមានចេតនាក្នុងការប្រព្រឹត្តបទល្មើស **"ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍"** នោះទេ ប៉ុន្តែមិនមានភស្តុតាង ឬសាក្សី ដោះបន្ទុកបញ្ជាក់ថា កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចនេះការលើកឡើងរបស់មេធាវីនោះទេ មិនអាចឱ្យតុលាការពិចារណាបាន។ ចំពោះការយកលុយរបស់ឈ្មោះ [redacted] សុផាត នោះជារឿងរដ្ឋប្បវេណីដោយមានកិច្ច



Scanned with CamScanner

សន្យាខ្ចីប្រាក់ប៉ុណ្ណោះ នេះគ្រាន់តែជាកិច្ចសន្យាដោយជនជាប់ចោទយកលុយចាយវាយអស់ពុំបានបង្វិលឱ្យម្ចាស់ដើមវិញ និងធ្វើការរត់ការតាមសំណូមពររបស់ជនរងគ្រោះឡើយ។

១៣-មានភស្តុតាង និងមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted]ម៉ារី ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ មានសាវតារជាតិដូចខាងលើ ពីបទ "**បរិហាកេរ្តិ៍ជាសាធារណៈ, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍, ញុះញង់ឱ្យមានការរើសអើង និងស្អប់ខ្ពើមថ្នាក់ដឹកនាំ និងស្ថាប័នក្រសួងការពារជាតិ**" ប្រព្រឹត្តនៅតាមបណ្ដាញFacebook name [redacted]Ka និងTelegram កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ រហូតដល់មានបណ្ដឹង **តាមបញ្ញត្តិមាត្រា៤៩៤, មាត្រា៤៩៥, មាត្រា ៣០៥ និងមាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** និងពីបទ "**ឆបោក**" ប្រព្រឹត្តនៅទីស្ដីការក្រសួងការពារជាតិ ស្ថិតនៅសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ **តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ**។

១៤-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផាត បានទាមទារប្រាក់ដើម និងសំណងជម្ងឺចិត្តចំនួន ៥០.០០០ (ប្រាំម៉ឺន)ដុល្លារអាមេរិក។

១៥-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆ័យណា បានទាមទារសំណងជម្ងឺចិត្តចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក អាចឱ្យតុលាការពិចារណាបាន។

១៦-វត្ថុតាងរួមមាន៖ ទូរស័ព្ទម៉ាក OPPO Find N2ពណ៌ទឹកមាស (ចាស់)ចំនួន ០១គ្រឿង, ទូរស័ព្ទម៉ាក OPPO Reno ពណ៌ទឹកប្រាក់ ចំនួន ០១គ្រឿង គប្បីតុលាការ ពិនិត្យ និងសម្រេច រឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋ។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ម៉ារី ភេទស្រី អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មានសាវតារជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ១៨ (ដប់ប្រាំបី) ខែ តែទោសនេះត្រូវព្យួរទាំងអស់។

ពីបទ "**បរិហារកេរ្តិ៍ជាសាធារណៈ, ញុះញង់ឱ្យប្រព្រឹត្តអំពើឧក្រិដ្ឋជាអាទិ៍, ញុះញង់ឱ្យមានការរើសអើង និងស្អប់ខ្ពើមថ្នាក់ដឹកនាំ និងស្ថាប័នក្រសួងការពារជាតិ**" ប្រព្រឹត្តនៅតាមបណ្ដាញ Facebook (ហ្វេសបុក) ឈ្មោះ [redacted]Ka និង Telegram កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ រហូតដល់មានបណ្ដឹង តាមបញ្ញត្តិមាត្រា៣០៥, **មាត្រា ៤៩៤ និងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** និងបទ "**ឆបោក**" ប្រព្រឹត្តនៅទីស្ដីការក្រសួងការពារជាតិ ស្ថិតនៅសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៣៧៧ **និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ១០៧ តាមក្រមព្រហ្មទណ្ឌ**។

២-រឹបអូសវត្ថុតាងរួមមាន៖ ទូរស័ព្ទម៉ាក OPPO Find N2ពណ៌ទឹកមាស (ចាស់)ចំនួន ០១គ្រឿង, ទូរស័ព្ទម៉ាក OPPO Reno ពណ៌ទឹកប្រាក់ ចំនួន ០១គ្រឿង។

៣-បង្គាប់ឱ្យឈ្មោះ [redacted]ម៉ារី ៖

ក. សងសំណងជម្ងឺចិត្តចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណី



Scanned with CamScanner

ឈ្មោះ [redacted] ផ័យណា ចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ ការទាមទារលើសពីនេះបដិសេធចោល។

ខ. សងសំណងការខូចខាតចំនួន ៣០.៣០០ (បីម៉ឺនបីរយ) ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សូផាត ចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ ការទាមទារលើសពីនេះបដិសេធចោល។

-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ម៉ារី និង ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សូផាត និងឈ្មោះ [redacted] ផែណារ ទុកពេលប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

.......................................................................................................................

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ០៤កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
កំពង់ធំ,ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤
**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner